3112

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តបាត់ដំបង**

សាលក្រមព្រហ្មទណ្ឌ

លេខ : ០៩ "ជ" ចុះថ្ងៃទី

២១ ខែមិនា ឆ្នាំ២០០៨

សំណុំរឿងព្រហ្មទណ្ឌ

លេខ : ៣២៨ ចុះថ្ងៃទី១១

ខែឧសភា ឆ្នាំ២០០៧

## នាមនាចប្រជារាស្ត្រខ្មែរ

## សាលាដំបូងខេត្តបាត់ដំបង

បង្កើតឡើងតាមច្បាប់អំពីការចាត់តាំង និង សកម្មភាពសាលាជម្រះក្តីនៃរដ្ឋកម្ពុជា ប្រកាសឱ្យប្រើតាមក្រឹត្យលេខ : ០៦ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ ។ បានបើកសវនាការជាសាធារណៈ នៅសាលាដំបូងខេត្តបាត់ដំបង ថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០០៨ និង ប្រកាសជាសាធារណៈនៅថ្ងៃទី២៦ ខែមីនា ឆ្នាំ២០០៨ ។ ដែលមានសមាសភាពដូចខាងក្រោម :

-លោក [redacted] ជាចៅក្រមជំនុំជម្រះ

-លោក [redacted] ជាតំណាងអយ្យការ

-លោក [redacted] ជាក្រឡាបញ្ជីសវនាការ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ : ៣២៨ ចុះថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០០៧ ដែលមានជនជាប់ចោទឈ្មោះ :

១-ឈ្មោះ [redacted] សំណាង ភេទប្រុស អាយុ២២ឆ្នាំ ជាតិខ្មែរ សញ្ជាតិខ្មែរ កើតនៅភូមិព្រៃម្ទ ឃុំកំពង់ឈ្នក ស្រុកកោះអណ្តែត ខេត្តតាកែវ កសិករប្បធម៌ ថ្នាក់ទី០៦ថ្មី សាសនាព្រះពុទ្ធ ទីលំនៅសព្វថ្ងៃ[redacted] ស្រុកកំរៀង ខេត្តបាត់ដំបង មុខរបរធ្វើចំការ នៅលីវ ឪពុកឈ្មោះ[redacted] "រស់" ម្តាយឈ្មោះ [redacted] "រស់" ទោសពីមុនគ្មាន ។

២-ឈ្មោះ[redacted] សំអុល ភេទប្រុស អាយុ២០ឆ្នាំ ជាតិខ្មែរ សញ្ជាតិខ្មែរ កើតនៅភូមិព្រៃម្ទ ឃុំកំពង់ឈ្នក ស្រុកកោះអណ្តែត ខេត្តតាកែវ កសិករប្បធម៌ ថ្នាក់ទី០៣ថ្មី សាសនាព្រះពុទ្ធ ទីលំនៅសព្វ[redacted] ស្រុកកំរៀង ខេត្តបាត់ដំបង មុខរបរ ជាងធ្វើម៉ូតូ នៅលីវ ឪពុកឈ្មោះ [redacted] "រស់" ម្តាយឈ្មោះ [redacted] "រស់" ទោសពីមុនគ្មាន ។

ជាប់ចោទពីបទ " បង្កអគ្គីភ័យដោយចេតនា " ប្រព្រឹត្តនៅភូមិអូរចំបក់ ឃុំត្រាង ស្រុកកំរៀង ខេត្តបាត់ដំបង កាលពីថ្ងៃទី ២៨ ខែតុលា ឆ្នាំ២០០៦ តាមបញ្ញត្តិមាត្រា ៥៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] រ៉ុម ភេទស្រី អាយុ៣៩ឆ្នាំ ជាតិខ្មែរ សញ្ជាតិខ្មែរ ទីលំនៅសព្វថ្ងៃនៅ [redacted]ស្រុកកំរៀង ខេត្តបាត់ដំបង ។

-ប្តឹងទាមទារសំណងការខូចខាតចំនួន ២៥០.០០០(ម្ភៃប្រាំម៉ឺន) បាត ។

## ការប្រព្រឹត្តរបស់ជនជាប់ចោទ

កាលពីថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៦ វេលាម៉ោង១០ និង ៣០នាទីយប់មានជនល្មើសមួយក្រុម បានលបលួចដុតជង្រុកពោតដែលមានទទឹង ០៧ម៉ែត្រ និង បណ្តោយ ០៨ម៉ែត្រ ផ្ទុកពោត និង សណ្តែកពេញប្រមាណ ១៨តោន និងសម្ភារៈច្រើនទៀតនៅក្នុងនោះ បណ្តាលអោយឆេះមិនសល់ខ្ទេចខ្ទី ដោយម្ចាស់ផ្ទះវិលមកលក់សណ្តែកនៅឃុំបឹងរាំង ។

-បានឃើញរបាយការណ៍លេខ : ២៤/២០០៦ របស់ប៉ុស្តិ៍នគរបាលរដ្ឋបាលត្រាង ចុះថ្ងៃទី ២៩ ខែ តុលា ឆ្នាំ ២០០៦ ។

-បានឃើញ ដីកាបញ្ជូនរឿងឱ្យជំនុំជម្រះលេខ : ៤០៥ ពស/ព្រទ ចុះថ្ងៃ១២ ខែកុម្ភៈ ឆ្នាំ២០០៨ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តបាត់ដំបង ។



Scanned by CamScanner

## នាពេលសវនាការ

-តំណាងអយ្យការធ្វើសេចក្ដីសន្និដ្ឋានស្ថាពរលេខ ២២៧ ជសសព ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០០៨

-ជនជាប់ចោទឈ្មោះ [redacted] សំអុល បានបញ្ជាក់នាពេលសវនាការថា : នៅថ្ងៃនោះខ្លួនពុំបានដុតភ្លើងអ្វីទេ ខ្លួនមិនដឹងភ្លើងឆេះជង្រុក [redacted] រ៉ុមទេ ។

-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] រ៉ុម បានបញ្ជាក់នាពេលសវនាការថា : នៅថ្ងៃនោះខ្លួនអង្គុយជាមួយយាយហន ហើយឃើញ [redacted] សំណាង និង [redacted] សំអុល អង្គុយសំឡក់ខ្លួន ១ប្ដឹងទាមទារសំណង ២៥លានរៀល ខ្លួនខូចខាតជង្រុកពោត.សណ្ដែក.ភ្លាំង ចាន និង សុំអោយតុលាការផ្ដន្ទាទោស ។

-សាក្សីឈ្មោះ [redacted] យឿន បានបញ្ជាក់នាពេលសវនាការថា : ម៉ោង៦ល្ងាច ខ្លួនទៅបត់ជើងធំ ខ្លួនឃើញឈ្មោះ ណាង និង អុល ដុតភ្នក់ភ្លើងចំងាយ ១ម៉ែត្រពីជង្រុក រហូតម៉ោង១០យប់ភ្លើងឆេះពេញ រហូតម៉ោង១២ទើបរលត់ ខ្លួននៅឆ្ងាយពីវាប្រហែល៥ម៉ែត្រ ។

-សាក្សីឈ្មោះ [redacted] ហ៊ី បានបញ្ជាក់នាពេលសវនាការថា : ខ្លួនមិនបានឃើញឈ្មោះ [redacted] និង អុលទេនៅថ្ងៃនោះ ខ្លួនអត់ដឹងភ្លើងឆេះជង្រុកទេ នៅថ្ងៃនោះទូរទស្សន៍ផ្ទះខ្លួនខូចទេ មិនឃើញឈ្មោះ ណាង និង អុលទេ ។

-ជនជាប់ចោទឈ្មោះ [redacted] សំអុល បានបញ្ជាក់នាពេលសវនាការថា : ខ្លួនពុំមានសាក្សីទេ នៅថ្ងៃនោះខ្លួនទៅម៉ោង៣ មិនមែនល្ងាចទេ ។

## តំណាងអយ្យការធ្វើសេចក្ដីសន្និដ្ឋាន

ឆ្លងតាមពេលសវនាការឃើញថា ពិតជាមានអំពើបង្កអគ្គីភ័យដោយចេតនាកើតឡើងនៅចំណុចភូមិអូរចំបក់ ឃុំព្រាង ស្រុកកំរៀង ខេត្តបាត់ដំបង កាលពីថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៦ ពិតប្រាកដមែន ។

តម្កល់បទចោទប្រកាន់តាមដីកាសន្និដ្ឋានស្ថាពរទុកនៅត្រឹមត្រូវដដែល និង សុំអោយតុលាការផ្ដន្ទាទោសតាមច្បាប់ ។

## សំដីចុងក្រោយរបស់ជនជាប់ចោទ

-ជនជាប់ចោទឈ្មោះ [redacted] សំអុល បានបញ្ជាក់នាពេលសវនាការថា : សុំអោយតុលាការជួយរកយុត្តិធម៌ ។

-ក្រោយពីបានស្ដាប់ចំលើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្ដាប់អំណានជនជាប់ចោទឈ្មោះ [redacted] សំអុល

-ក្រោយពីបានស្ដាប់ចំលើយដើមបណ្ដឹងរដ្ឋប្បវេណីអោយការណ៍ និង ប្ដឹងសុំ

-ក្រោយពីបានស្ដាប់ចំលើយសាក្សី

-ក្រោយពីបានស្ដាប់ការសួរដេញដោល

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានពិនិត្យភស្តុតាង និង ឯកសារផ្សេងៗក្នុងសំណុំរឿង

-ក្រោយពីបានពិនិត្យពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សាលាដំបូងខេត្តបាត់ដំបង

## យល់ឃើញថា

-កាលពីថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៦ នោចំណុចភូមិអូរចំបក់ ឃុំព្រាង ស្រុកកំរៀង ខេត្តបាត់ដំបង មានករណីបង្កអគ្គីភ័យដោយចេតនាមួយបានកើតឡើង ដែលបង្កដោយជនជាប់ចោទឈ្មោះ [redacted] សំណាង ភេទប្រុស អាយុ២១ឆ្នាំ ( មានសាវតាជាតិ ) និង ឈ្មោះ [redacted] សំអុល ភេទប្រុស អាយុ១៩ឆ្នាំ ( មានសាវតាជាតិ ) ដែលត្រូវអោយផ្ដន្ទាទោសតាមមាត្រា៥៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។



Scanned by CamScanner

-តាមចំលើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted]ម បានបញ្ជាក់ថាខ្លួនបានសង្កេតឃើញជនជាប់ចោទឈ្មោះ[redacted] សំណាង និង ឈ្មោះ [redacted]អុល បានសំឡក់សំឡឹងមិនដឹងថាមានតំនុំអ្វីជាមួយខ្លួនឡើយ ហើយដែលថ្ងៃនោះ តាមចំលើយសាក្សីឈ្មោ[redacted]យុន បានបញ្ជាក់ថា បានឃើញជនជាប់ចោទទាំងពីរ មុនពេលកើតហេតុជនជាប់ចោទទាំងពីរនៅកន្លែងកើតហេតុ ។

-តាមចំលើយសាក្សីឈ្មោះ[redacted]ហ៊ី បានបញ្ជាក់ថា ជនជាប់ចោទបានទៅមើលទូរទស្សន៍នៅផ្ទះខ្លួននោះ គឺមិនពិតទេ ព្រោះអាគុយបានខូចយូរហើយ ដែលចំលើយនេះ តុលាការពុំអាចជឿបានឡើយ ។

-ទង្វើរបស់ជនជាប់ចោទទាំងពីរនេះ គឺមានធាតុផ្សំគ្រប់គ្រាន់ដើម្បីធ្វើការផ្តន្ទាទោសតាមមាត្រា៥៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

-ដើមបណ្តឹងរដ្ឋប្បវេណីប្តឹងទាមទារសំណង និង ជំងឺចិត្តចំនួន ២៥លានរៀល ប៉ុន្តែពុំបានបង្ហាញភស្តុតាងណាមួយពីព្យសនកម្មដែលកើតឡើងពីអំពើខាងលើទេ ដែលតុលាការពុំអាចពិចារណាបាននាពេលនេះ ដូច្នេះតុលាការគប្បីទុកសិទ្ធិអោយដើមបណ្តឹងរដ្ឋប្បវេណីប្តឹងសុំទៅតុលាការរដ្ឋប្បវេណីនាពេលក្រោយ នៅពេលមានសំណងគ្រប់គ្រាន់អំពីព្យសនកម្ម និង ជំងឺចិត្ត ។

**ហេតុដូច្នេះសាលាដំបូងខេត្តបាត់ដំបង**

**វិនិច្ឆ័យសេចក្តី**

១-ផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted]សំអុល ភេទប្រុស អាយុ១៩ឆ្នាំ (មានសាវតាជាតិ) និង ឈ្មោះ [redacted] សំណាង ភេទប្រុស អាយុ២១ឆ្នាំ (មានសាវតាជាតិ) កំណត់ដាក់ពន្ធនាគាររយៈពេល ០១(មួយ)ឆ្នាំ គិតពីថ្ងៃសាលក្រមនេះចូលជាស្ថាពរ និង ឃុំខ្លួនក្នុងពន្ធនាគារ ពីបទ " បង្កអគ្គីភ័យដោយចេតនា " ប្រព្រឹត្តនៅភូមិអូរចំបក់ ឃុំក្រាង ស្រុកកំរៀង ខេត្តបាត់ដំបង កាលពីថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៦ តាមមាត្រា៥៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

២-ទុកសិទ្ធិអោយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] រុំម ប្តឹងទៅតុលាការផ្នែករដ្ឋប្បវេណីទាមទារសំណង និង ជំងឺចិត្តតាមក្រោយនៅពេលមានសំអាងគ្រប់គ្រាន់អំពីការខូចខាតដែលបង្កឡើងដោយឈ្មោះ [redacted] សំអុល និង ឈ្មោះ[redacted] សំណាង ។

៣-សាលក្រមនេះជំនុំជម្រះចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោ[redacted]ម និង ជនជាប់ចោទឈ្មោះ[redacted] សំអុល កំបាំងមុខជនជាប់ចោទឈ្មោះ[redacted]សំណាង នៅថ្ងៃទី១៤ ខែមិនា ឆ្នាំ២០០៨ និង ប្រកាសជាសាធារណៈនៅថ្ងៃទី២១ ខែមិនា ឆ្នាំ២០០៨ លើកផ្លូវប្តឹងទាស់ និង ប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

| | |
|---|---|
| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមជំនុំជម្រះ** |
| [redacted] | [redacted] |